# មេរៀនទី ៥០៖ ជនជាតិអ៊ីស្រាអែលរងទុក្ខជាទាសករ

## និក្ខមនំ ៥៖១- ៦៖១

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/ZlVUtQNfnxo

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/jQquVLW4Svs

**គោលបំណង៖** ព្រះគឺជាសេចក្ដីសង្ឃឹមរបស់យើង

**ខគម្ពីរចងចាំ៖ យេរេមា២៩៖១១** *"ដ្បិតព្រះយេហូវ៉ាមានព្រះបន្ទូលថា អញស្គាល់សេចក្ដីដែលអញគិតពីដំណើរឯងរាល់ គ្នា មិនមែនគិត ធ្វើសេចក្ដីអាក្រក់ទេ គឺគិតឲ្យបានសេចក្ដីសុខវិញ ដើម្បីដល់ចុងបំផុតឲ្យឯងរាល់គ្នាបាន សេចក្ដីសង្ឃឹម"។*

**ចំរៀង** ( *យូធូបលីង* )៖

១. ព្រះយេស៊ូវគឺជាព្រះអម្ចាស់ https://youtu.be/I-PzUIJ0MVo

២. ខ្ញុំចូលតាមទ្វារព្រះអង្គ https://youtu.be/WvXL4DtBMdc

៣. ខ្ញុំនឹងទុក្ខចិត្តទ្រង់ https://youtu.be/WCZlwlstAzc

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត

សម្ភារៈដែលត្រូវការៈ ពែង២, ទឹក, ស្ករស និង អំបិល




ថ្ងៃនេះប្រធានបទនៃមេរៀននិយាយពីសេចក្ដីសង្ឃឹម។

១. យកស្ករសលាយក្នុងទឹកមួយពែង និង មួយពែងទៀតសូមលាយជាមួយអំបិល (កុំឱ្យសិស្សឃើញពេលកំពុងលាយ)

២. នៅពេលលាយរួច សូមលើកបង្ហាញសិស្ស ដោយកុំប្រាប់សិស្សថាមួយណាជាទឹកអំបិល មួយណាជាទឹកស្ករ

៣. ឲ្យសិស្ស ២ នាក់ដើរមករកគ្រូ ក្នុងចំណោមពួកគេទាំងពីរឲ្យ សិស្សម្នាក់ជាអ្នកជ្រើសរើសកែវទឹកឲ្យសិស្សម្នាក់ទៀតជាអ្នកញ៉ាំ។

៤. សូមសួរទៅកាន់សិស្សទាំងពីរ តើពួកគេរំពឹងថា ទឹក ដែលនៅក្នុងពែងនោះជាទឹកអ្វី។

៥. បន្ទាប់មកឱ្យកុមារផឹកទឹកនោះ តើវាជាទឹកស្ករ? ឬជាទឹកអំបិល?

៦.បើសិនជាទឹកស្ករ សូមសួរ គាត់ថា តើកូនមានអារម្មណ៍យ៉ាងណាដែរ នៅពេលដែលកូនទទួលបាននូវអ្វីដែលកូនរំពឹងចង់ បាន? ព្រះពិតជា មានអំណាចអស្ចារ្យ ព្រោះទ្រង់អាចប្រទាននូវអ្វីដែលយើងសង្ឃឹមចង់បាន!

៧.បើកុមារផឹកចំទឹកអំបិល សូមសួរគាត់ថាតើកូនមានអារម្មណ៍បែបណា នៅពេលដែលមិនទទួលបានអ្វីដែលកូនរំពឹងចង់បាន?

៨.មនុស្សមួយចំនួនអាចគិតថាយើងកំពុងជួបការខកចិត្តព្រោះយើង មិនបាន ទទួលនូវអ្វីដែលយើងរំពឹងចង់បាន។ ពេលខ្លះជីវិតគឺបែបនេះហើយ យើងអាចនឹងជួបការ ខកចិត្ត តែព្រះនឹងមិនដែល ធ្វើឱ្យ

យើងខកចិត្តទេ អញ្ចឹងហើយបានជាព្រះគម្ពីរប្រាប់យើងឱ្យដាក់ក្តីសង្ឃឹមនៅលើព្រះ មិនមែនលើមនុស្សទេ ព្រះគឺជា សេចក្តីសង្ឃឹមតែ១គត់ ដែលនឹង មិនធ្វើឱ្យយើងខកចិត្តឡើយ។

## ៤. ការណែនាំមេរៀន

ការដែលមានក្តីសង្ឃឹមមានន័យថាអ្វីដែលយើងចង់បាននឹងកើតឡើង។ ព្រះតែងតែស្រឡាញ់យើង ហើយចង់ឱ្យយើងសង្ឃឹមលើអ្វីដែលល្អ ពេលខ្លះព្រះប្រទានពរឱ្យយើងភ្លាមៗនូវអ្វីដែលយើងរំពឹងចង់បាន។ ប៉ុន្តែពេលខ្លះព្រះមានបន្ទូលថា ទេ ពីព្រោះទ្រង់ដឹងថាអ្វីៗទាំងនោះមិនល្អទេសម្រាប់យើង ឬ ដោយសារតែនៅក្នុងព្រះទយ័ទ្រង់មានអ្វីដែលល្អប្រសើរជាងនេះសំរាប់យើង។ ហើយពេលខ្លះព្រះមានបន្ទូលថា "ចាំសិន—មិនមែនពេលនេះទេ" ពេលវេលារបស់ទ្រង់គឺល្អឥតខ្ចោះ។ ជនជាតិអ៊ីស្រាអែលដែលជាប់ជាទាសករនៅអេហ្ស៊ីបអស់រយៈពេល៤០០ឆ្នាំ!ពួកគេសង្ឃឹមថានឹងមានសេរីភាពឡើងវិញប៉ុន្តែពួកគេត្រូវតែរងចាំ។ (គ្រូៈ សូមនិយាយដោយសង្ខេបពីពេលមួយនៅក្នុងជីវិតរបស់ អ្នកនៅពេលដែលអ្នកបានអធិស្ឋានសុំអ្វីមួយដោយសង្ឃឹមចង់បានហើយព្រះបានឆ្លើយតបនូវការអធិស្ឋាននោះ។ សួរសិស្សថាប្រសិនបើពួកគេចង់បានអ្វីមួយ នៅពេលដែលគេអធិស្ឋានសុំ ហើយព្រះនឹងឆ្លើយតប តើពួកគេនិងសុំអ្វីពីព្រះ។)

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ត្រលប់ទៅកាន់សម័យលោកម៉ូសេ ជនជាតិអ៊ីស្រាអែលដែលជារាស្ត្ររបស់ព្រះបានធ្វើជាទាសកររបស់មេដឹកនាំអាក្រក់ម្នាក់ឈ្មោះផារ៉ោន។ ផារ៉ោនគឺជាស្តេចនៃប្រទេសអេហ្ស៊ីប គាត់បានធ្វើបាបជនជាតិ អ៊ីស្រា-អែលជាខ្លាំង។ ជនជាតិអ៊ីស្រាអែលត្រូវធ្វើដុំឥដ្ឋចេញពីភក់ និងចំបើងសំរាប់សាងសង់អាគារឲ្យ ស្តេចផារ៉ោន។ ជារៀងរាល់ថ្ងៃផារ៉ោនកាន់តែធ្វើអាក្រក់ទៅៗដាក់ជនជាតិអ៊ីស្រាអែល។ ផារ៉ោនបានឱ្យពួក គេធ្វើការកាន់តែច្រើនឡើងៗ ដោយប្រើសំភារៈជំនួយតិចទៅៗ។ ជនជាតិអ៊ីស្រាអែលខ្លាច ផារ៉ោន ណាស់។ ព្រះបានលឺសម្រែកទ្រហោយំរបស់រាស្ត្រទ្រង់ ហើយទ្រង់ទតរកមើលនរណាម្នាក់ ដែលអាចដឹកនាំជនជាតិអ៊ីស្រាអែលចេញពីភាពជាទាសករនេះបាន។ ព្រះបានជ្រើសរើសម៉ូសេក្នុង ចំណោមជនជាតិអ៊ីស្រាអែលទាំងអស់សម្រាប់ធ្វើការងារមួយនេះ។ ម៉ូសេមិនមានទំនុកចិត្ត ទាំងស្រុងថា គាត់អាចដឹកនាំរាស្ត្ររបស់ព្រះបានទេ ប៉ុន្តែគាត់ទុកចិត្តនិងសង្ឃឹមលើព្រះ។ ម៉ូសេនិងជនជាតិអ៊ីស្រាអែល បានរង់ចាំព្រះដើម្បីបង្ហាញផ្លូវពួកគេចេញពីអេហ្ស៊ីប ។ ជនជាតិអ៊ីស្រាអែលបានរង់ចាំហើយចាំទៀត រហូតដល់ទ្រង់យាងមក! ព្រះបានជួយពួកគេឱ្យរួចផុតពីភាពជាទាសកររបស់ផារ៉ោន។ នោះហើយគឺជាព្រះទ្រង់ធ្វើអ្វីដែលទ្រង់និយាយថាទ្រង់នឹងធ្វើ!

មនុស្សគ្រប់គ្នាមានបញ្ហា ពេលខ្លះយើងមានអារម្មណ៍ថាយើងនៅឯកា ធុញទ្រាន់ និងក្រៀមក្រំដូចជាជនជាតិអ៊ីស្រាអែលដែរ។ ប៉ុន្តែការចែករំលែកការឈឺចាប់ និង បញ្ហារបស់យើងជាមួយនរណាម្នាក់ ធ្វើឱ្យយើងមានអារម្មណ៍ថាមិនឯកាឡើយ វាជួយពង្រឹងនូវសេចក្តីជំនឿរបស់យើង ហើយជួយយើងឲ្យមានក្តីសង្ឃឹមលើព្រះដើម្បីឱ្យយើងឆ្លងកាត់គ្រាលំបាកនោះ។ ការដែលមានក្តីសង្ឃឹមលើព្រះធ្វើឱ្យយើងរឹងមាំ ហើយអាចឆ្លងកាត់គ្រាលំបាកទាំងនោះបាន។

## ៦. សំនួរពិភាក្សា

១.តើអ្នកណាបានធ្វើអាក្រក់ដាក់ជនជាតិអ៊ីស្រាអែល? (*ផារ៉ោន*)

២.តើព្រះបានជ្រើសរើសអ្នកណាដើម្បីសង្គ្រោះជនជាតិអ៊ីស្រាអែល? (*ម៉ូសេ*)

៣.តើម៉ូសេសង្ឃឹមលើអ្នកណានៅពេលដែលគាត់មិនមានទំនុកចិត្តលើខ្លួនឯង? (*ព្រះ*)

៤.តើព្រះតែងតែធ្វើអ្វីដែលទ្រង់និយាយថាទ្រង់នឹងធ្វើដែរឬទេ?

*( បាទ,ចាស់!ព្រះមិនដែលភ្លេចអ្វីដែលទ្រង់សន្យាជាមួយយើងទេ។ ពេលខ្លះយើងត្រូវរង់ចាំ តែព្រះតែងតែធ្វើតាមការសន្យារបស់ទ្រង់។)*

៥. នៅពេលមានបញ្ហានិងការទុកលំបាក តើប្អូនៗស្វែងរកអ្នកណាឱ្យជួយ?

**៧. ល្បែងកំសាន្ត** ***«ស្វែងរកកំណប់ »***

សំភារៈដែលត្រូវការ៖ ក្រដាស់១០សន្លឹកដែលមានពាក្យថា “ក្តីសង្ឃឹម” សរសេរលើក្រាស់ទាំងនោះ




១.មុនពេលកុមារមកដល់ក្នុងថ្នាក់ គ្រូត្រូវសរសេរពាក្យ “ សេចក្តីសង្ឃឹម” លើក្រដាស ១០សន្លឹកហើយលាក់

២.វានៅកន្លែងផ្សេងៗគ្នាក្នុងថ្នាក់។ ហើយឱ្យសិស្សដើររកក្រដាសទាំងនោះ។

៣. រៀបចំរង្វាន់តូចមួយសម្រាប់អ្នកឈ្នះ។

**៨. ខគម្ពីរចងចាំ**

**យេរេមា ២៩៖១១** *“ដ្បិតព្រះយេហូវ៉ាមានព្រះបន្ទូលថា អញស្គាល់សេចក្តីដែលអញគិតពីដំណើរឯងរាល់គ្នា មិនមែនគិត ធ្វើសេចក្តីអាក្រក់ទេ គឺគិតឲ្យបានសេចក្តីសុខវិញ ដើម្បីដល់ចុងបំផុតឲ្យឯងរាល់គ្នាបានសេចក្តីសង្ឃឹម”។*

**៩. ហាត្ថកម្ម**

សូមផាត់ពណ៌រូបជនជាតិអ៊ីស្រាអែលកាលនៅជាទាសករ ( *សូមមើលរូបខាងក្រោម*)

**១០. ចំរៀង** *( ជ្រើសរើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស )*

**១១.អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ ( សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន )**
ព្រះមិនបានសន្យាជាមួយអ្នកដើរតាមទ្រង់ថា ជីវិតនឹងគ្មានបញ្ហានោះទេ ប៉ុន្តែក្នុងនាមជាអ្នកដើរតាមព្រះយេស៊ូវយើងមានសង្ឃឹម ទោះបីស្ថិតក្នុងស្ថានភាពលំបាកក៏ដោយ។ ជនជាតិហេព្រើរបាត់បង់ក្តីសង្ឃឹម ហើយយើងពិតជាអាចយល់ពីមូលហេតុ! ប៉ុន្តែព្រះមិនដែលឈប់មានផែនការសម្រាប់អនាគតរបស់ពួកគេឡើយ។ តើអ្នកមានសង្ឃឹមអ្វីនៅថ្ងៃនេះ? សូមចងចាំថាព្រះកំពុងធ្វើការសំរាប់អនាគតរបស់អ្នក បើទោះបីជាវាមើលទៅហាក់ដូចជាមិនអាចទៅរួចក៏ដោយ។ សូមអរគុណព្រះយេស៊ូវចំពោះវត្តមានរបស់ទ្រង់នៅក្នុងដំណើរជីវិតរបស់អ្នក។

សូមសរសេរខគម្ពីរចងចាំ:



សូមសរសេរខគម្ពីរចងចាំ:

